00197558

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

C22/I/41

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៣)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នៃយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 24 / 06 / 2008
ម៉ោង (Time/Heure): 15:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

កាលបរិច្ឆេទ: ២៤ មិថុនា ២០០៨

# សេចក្តីសម្រេចទទួលយកសេចក្តីសន្និដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណី

**សហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**ជនត្រូវចោទ**
អៀង សារី

**សហមេធាវីការពារក្តី**
អាង ឧត្តម
Michael G. KARNAVAS

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
Silke Studzinsky

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 24 / 06 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

00197559



១. **អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** (“**អវតក**”) បានទទួលសេចក្តីសង្កេតជាទូទៅពី “សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី” ដែលបានដាក់នៅ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ (“សេចក្តីសង្កេត”) ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន ជនត្រូវចោទ **អៀង សារី** ដែលជាក់ស្តែង ជាពាក្យសុំសេចក្តីណែនាំ។

២. យោងតាមសេចក្តីសង្កេតនេះ សហមេធាវីលើកឡើងថា “សេចក្តីបង្គាប់ស្តីពីសេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងពេលសវនាការបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន” ដែល ដែលជាសេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៨ លើបណ្តឹងឧទ្ធរណ៍របស់ **អៀង ធីរិទ្ធ** មានការរើសអើងដើមបណ្តឹងរដ្ឋប្បវេណីលើសិទ្ធិនីតិវិធីក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធី។ ម៉្យាងវិញទៀត សហមេធាវីលើកឡើងថា វិធានចែងនៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក និងការបែងចែងរយៈពេលមិនស្មើគ្នាក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ ក្នុងសវនាការបណ្តឹងឧទ្ធរណ៍លើការឃុំខ្លួនបណ្តោះអាសន្ន មានអនុភាពរើសអើង។

៣. នៅក្នុង “សេចក្តីសម្រេចស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសវនាការបណ្តឹងឧទ្ធរណ៍លើការឃុំខ្លួនបណ្តោះអាសន្ន” ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានសម្រេចអនុញ្ញាតការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងពេលសវនាការបណ្តឹងឧទ្ធរណ៍លើការឃុំខ្លួនបណ្តោះអាសន្ន ហើយអង្គបុរេជំនុំជម្រះបានសម្រេចថា នីតិវិធី អ.វ.ត.ក ត្រូវអនុញ្ញាតការចូលរួមបែបនេះជាដាច់ខាត។ បន្ថែមលើចំនុចនេះ អង្គបុរេជំនុំជម្រះបានបញ្ជាក់ច្បាស់ហើយថា ការធានាតុល្យភាពរវាងសិទ្ធិនីតិវិធីរបស់ភាគីទាំងឡាយ មានសារៈសំខាន់ និងជាដំណើរការកំពុងបន្ត។ អង្គជំនុំជម្រះអាចចេញសេចក្តីបង្គាប់លើនីតិវិធីបែបនេះ ដោយសារវាជាការសមស្របក្នុងការចាត់ចែងលើកិច្ចដំណើរការនីតិវិធី។ សេចក្តីបង្គាប់ទាំងនេះ បិទផ្លូវតវ៉ា ប៉ុន្តែអាចបើកឱ្យធ្វើការពិចារណាសារជាថ្មី ក្នុងករណីមានកាលៈទេសៈថ្មីលេចឡើង។

៤. សេចក្តីសង្កេតទាំងនេះ មិនបានលើកទឡ្ហីករណ៍ជាក់លាក់ដើម្បីឱ្យធ្វើការពិចារណាសារជាថ្មីលើសេចក្តីបង្គាប់ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៨ ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ **អៀង សារី** ដែលនៅចំពោះមុខ។ ហេតុដូច្នេះហើយ អង្គបុរេជំនុំជម្រះបដិសេធមិនទទួលយកសេចក្តីសង្កេតទាំងនេះ។

៥. អង្គបុរេជំនុំជម្រះ មិនមានសមត្ថកិច្ចធ្វើការពិចារណាការបដិសេធលើការកែប្រែសេចក្តីណែនាំអនុវត្តរបស់ អ.វ.ត.ក ឡើយ ហើយក្នុងករណីនេះ អង្គបុរេជំនុំជម្រះក៏បដិសេធមិនទទួលយកសេចក្តីសង្កេតទាំងនេះដែរ។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. E.T.C.

៦. ទឡ្ហីករណ៍ស្ដីពីរយៈពេលនៃការធ្វើសេចក្ដីសន្និដ្ឋានផ្ទាល់មាត់ គឺលើកឡើងក្នុងន័យទូទៅ និងក្នុងកម្រិតជាសំណើលើការបំពេញកិច្ច ដែលជាគោលការណ៍បែងចែករយៈពេលស្មើគ្នាក្នុងការធ្វើសេចក្ដីសន្និដ្ឋានផ្ទាល់មាត់ដល់ភាគីទាំងអស់។ អង្គបុរេជំនុំជម្រះមិនអាចបំពេញកិច្ចដូច្នេះបានឡើយ។ រយៈពេលដែលផ្ដល់ជូនតាំងពីមុនមក គឺបានផ្អែកលើភាពចាំបាច់ក្នុងការធានាតុល្យភាពរវាងសិទ្ធិរបស់ភាគី ដោយពិចារណាថា ភាគីទាំងអស់គាំទ្រលើការចោទប្រកាន់។ រយៈពេលបន្ថែមអាចត្រូវបានផ្ដល់ជូន ក្នុងករណីអង្គបុរេជំនុំជម្រះយល់ឃើញថាចាំបាច់ ហើយ ដូចគ្នានេះដែរ សេចក្ដីសន្និដ្ឋានជាន់គ្នា ឬមិនពាក់ព័ន្ធរបស់ភាគីទាំងឡាយ អាចត្រូវកម្រិត។

៧. តាមការកត់សម្គាល់ សេចក្ដីសម្រេច ឬសេចក្ដីបង្គាប់ដែលចុះហត្ថលេខាដោយប្រធានអង្គបុរេជំនុំជម្រះ តាងនាមឱ្យអង្គជំនុំជម្រះត្រូវបានសម្រេចដោយអង្គជំនុំជម្រះទាំងមូល។

**ហេតុដូច្នេះអង្គបុរេជំនុំជម្រះសម្រេច:**

មិនទទួលយកសេចក្ដីសង្កេតផ្នែកមួយចំនួន។

ចំពោះសេចក្ដីសង្កេតដែលអង្គបុរេជំនុំជម្រះទទួលយក អង្គបុរេជំនុំជម្រះនឹងមិនចេញសេចក្ដីបង្គាប់ថ្មីណាមួយឡើយ ដោយផ្អែកលើមូលដ្ឋាននេះ នៅក្នុងដំណាក់ការនេះ។ ៗ

ភ្នំពេញ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ប្រាក់ គឹមសាន